# ភ្លេងប្រដាល់

ប្រដាល់ គឺជាកីឡាដ៏ល្បីមួយក្នុងចំណោមកីឡាដែលមានប្រជាប្រិយនៅប្រទេសកម្ពុជា ជាពិសេសប្រដាល់សេរី ឬដែលគេស្គាល់និងនិយមហៅជាទូទៅថា «គុនខ្មែរ» ដែលយើងឃើញមានជាភស្តុតាងជាក់ច្បាស់ដោយចម្លាក់នៅលើជញ្ជាំង សិលាប្រាសាទ ទូទាំងប្រទេសកម្ពុជា ជាពិសេសប្រាសាទបាពួន អង្គរវត្ត និងបាយ័នជាដើម។

ព្រឹត្តិការណ៍និងកម្មវិធីកីឡាប្រដាល់នៅប្រទេសកម្ពុជា តែងតែត្រូវបានកំដរ ដោយវង់ភ្លេងមួយដែលមានឈ្មោះថា "វង់ភ្លេងប្រដាល់"។ ខ្មែរយើងទម្លាប់ហៅវង់ ភ្លេងនេះផ្សេងៗគ្នាទៅតាមទម្លាប់និងការហៅតៗគ្នា។ ខ្លះហៅវង់ភ្លេងនេះថា «វង់ភ្លេងក្លងខែក» មានន័យថា «ក្លង» គឺ «ស្គរ» ឯ «ខែក» គឺ «ផ្លុំឬតណ្ហា» ដូច្នេះ «ស្គរផ្លុំឬតណ្ហា» ដែលមានឧបករណ៍ភ្លេងស្រឡៃក្លងខែក ស្គរក្លងខែក និងឈិង។[1] ខ្លះទៀតហៅថា «ក្លងឆ្នាក់ឬក្លងឆ្នុះ» មានន័យថា «ស្គរឈ្នះ»។[2] ឯអ្នកខ្លះទៀត ហៅថា «ក្លងថ្នាក់» គឺគេប្រើចំនួនស្គរទៅតាមឋានៈ ជាពិសេសនៅពេលដែលគេប្រើវង់ភ្លេងនេះនៅក្នុងពិធីសព។[3]

ភ្លេងកំដរកីឡាប្រដាល់ខ្មែរ ឬគុនខ្មែរ មានពីរចំណែក៖ ថ្វាយបង្គំគ្រូ និងប្រដាល់។ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងកីឡាប្រភេទនេះ យើងឃើញមាន ចំបាប់ គុនខ្មែរ (ល្បុក្កតោ) និងប្រដាល់ ហើយនៅក្នុងអត្ថបទនេះ ខ្ញុំនឹងនិយាយ តែអំពីកីឡាប្រដាល់តែប៉ុណ្ណោះ។ ក្រោយពីកីឡាករប្រកួតទាំងសងខាងឡើងទៅលើសង្វៀនប្រដាល់រួចហើយ មុននឹងចាប់ប្រកួត កីឡាករត្រូវស្មឹងស្មាធិ៍ រឭកនឹកដល់គ្រូ ជាអ្នកប្រៀន ប្រៀនប្រដៅ និងថ្វាយបង្គំគ្រូ

---

[1] កែវ ណារុំ ២០១១: ២១៧

[2] កែវ ណារុំ ២០១១: ២១៧

[3] កែវ ណារុំ ២០១១: ២១៨

អត្ថបទដោយ៖

កំដរដោយបទ «យោន» ដែលមានន័យថា «បោះ» ឬ «ពួយ» និងវង់ភ្លេងប្រដាល់ដែលមានឧបករណ៍ ស្រឡៃនិងស្គរឈ្នះ។[៨]

ភ្លេងដែលគេជាទូទៅយកមកលេងកំដរក្នុងការប្រដាល់សេរីឬគុនខ្មែរ គឺមានតែមួយគត់។ ភ្លេងនេះមានន័យដ៏ពិសេសនិងស៊ីជម្រៅនៅក្នុងបេះដូងនិងអារម្មណ៍របស់ប្រជាជនខ្មែរ ដែលខ្មែរដឹងនិងចងចាំយ៉ាងច្បាស់ព្រមទាំងងាយស្រួលយល់ និងទាក់ទាញគេបាននៅពេលដែលគេបានឮនៅក្នុងព្រឹត្តិការណ៍កីឡាប្រដាល់។ ភ្លេងកំដរនេះមានពីរផ្នែកគឺ (១) ការបួងសួង រឭក អធិដ្ឋាន និង (២) ការប្រដាល់។ ការបួងសួងដល់ព្រលឹងឬ «គ្រូ» គឺដើម្បីឱ្យស្មារតីរបស់អ្នកប្រដាល់នោះស្ថិតនៅ នឹងធឹង និងផ្តល់ជាកម្លាំងចិត្តនិងពរជ័យដល់គេនៅក្នុងការប្រកួត។

ភ្លេង «យោន» ក្នុងផ្នែកទី១ គឺគ្មានចង្វាក់ទេ។ ឧបករណ៍ស្រឡៃលេង បទកំដរដោយស្គរ។ ឯភ្លេងប្រដាល់ក្នុងផ្នែកទី២ មានល្បឿនលឿនជាងផ្នែកទី១ កំដរដោយស្គរនៅក្នុងចង្វាក់មួយដែលនឹងនិងរៀបរយ។ នៅពេលដែលទឹកនីមួយៗ នៃការប្រកួតវិវត្តទៅមុខ ភ្លេងក៏បង្កើនល្បឿននិងរន្ធើនចង្វាក់ ទៅតាមសង្វាក់ អារម្មណ៍របស់អ្នកប្រដាល់ ហើយគេឈប់ប្រគំតែនៅពេលដែលទឹកនីមួយៗបានចប់ ឬនៅពេលដែលអ្នកប្រដាល់ណាមួយត្រូវបានគូប្រយុទ្ធវាយសន្លប់។ នៅក្នុងការប្រកួតណាដែលល្អ ទស្សនិកជនថែមទាំងចូលរួមទះដៃអបអរសាទរទៅតាមចង្វាក់ ភ្លេងទៀតផង។

សរុបសេចក្តីមក យើងឃើញថា វង់ភ្លេងនិងភ្លេងប្រដាល់នេះ មានតួនាទីសំខាន់ទាំងនៅក្នុងភិភពមនុស្សដែលនៅរស់នាបច្ចុប្បន្នកាលនិងពិភពក្រោមនុស្ស ពាក់ព័ន្ធនឹងព្រលឹងនៃគ្រូបាអាចារ្យអ្នកមានគុណដែលបានបាត់បង់ជីវិតទៅហើយ។ លើសពីនេះទៅទៀត បទដែលលេងសម្រាប់កំដរពេលថ្វាយបង្គំគ្រូ និងប្រដាល់ គឺពិតជាបទតាំងពីបរម

[៨] កែវ ណារុំ ២០១១: ២១៩

អត្ថបទដោយ៖

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

បុរាណកាលដែលមានឥទ្ធិពលចិត្តសាស្ត្រ ទាក់ទាញបេះដូង និងអារម្មណ៍របស់អ្នកស្តាប់ខ្មែរឱ្យមកសណ្ឋិតជាប់នៅជាមួយនឹង ព្រឹត្តិការណ៍និងសកម្មភាពប្រដាល់នេះតែម្តង។

## ឯកសារពិគ្រោះ

កែវ ណារុំ. (២០១១). *តន្ត្រីនៅប្រទេសខ្មែរ*. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត។

ជួន ណាត. (១៩៦៧). *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

Sam, Sam-Ang. (2002). *Musical Instruments of Cambodia.* Osaka: National Museum of Ethnology.

អត្ថបទដោយ៖



AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖